If you want a copy of the Notice of Privacy Practices, which is about your State-funded BCCTP privacy rights, call (916) 445-4646

إذا أردت نسخة من إشعار الممارسات الخاصة، الذي يتناول حقوق الممارسات الخاصة الخاصة بك، اتصل برقم
(Arabic) (916) 445-4646

Եթե ցանկանում եք ձեռք բերել Գաղտնիության Գործածման մասին Ծանուցման պատճեն, որը ձեր գաղտնիության իրավունքների մասին է, ապա զանգահարեք (916) 445-4546 եռախոսահամարով: (Armenian)

若閣下希望索取一份有關閣下私隱權的私隱處理通知書，請致電 (916) 445-4646 (Cantonese)

اگر مایل به دریافت نسخه ای از این اطلاعیه شیوه های تامین حریم خصوصی، که درباره حقوق حفظ حریم خصوصی شماست، می باشید با شماره تلفن (916) 445-4646 تماس بگیرید. (Farsi)

បើអ្នកចង់បានមួយច្បាប់នៃសេចក្តីជូនដំណឹងស្តីអំពីភាព លាក់ការណ៍ ដែលនិយាយអំពីសិទ្ធិនៃភាពលាក់ការណ៍របស់ អ្នក សូមហៅលេខ (916) 445-4646 (Khmer)

만약 귀하의 프라이버시 권리를 설명한, 프라이버시 관행에 관한 통지문 사본을 원하시면, (916) 445-4646로 전화하세요. (Korean)

Yog hais tias koj xav tau ib daim qauv ntawm Daim Ntawv Qhia Txog Cov Kev Ua Feem Nraim, uas hais txog koj cov cai feem nraim, hu rau (916) 445-4646 (Hmong)

**មានសារៈសំខាន់**

**** កម្មវិធីព្យាបាលជម្ងឺមហារីកសុដន់ និងដោះ ឥតមានឯកសារគ្រប់គ្រាន់នៃរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកទេ ។ ប្រសិនបើអ្នកចង់ពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នក យកឯកសារនៃរបាយការណ៍វេជ្ជសាស្ត្រ របស់អ្នក ឬកែប្រែរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នក ចូរទំនាក់ទំនងវេជ្ជបណ្ឌិតគ្លីនិក ឬគម្រោងថែទាំសុខភាពដែលបានចាត់ចែង ។ ****

- ស្នើសុំបញ្ជីមួយស្តីពីចំនួនដងនៃពេលវេលា ដែលយើងបានប្រាប់ព័ត៌មានពីសុខភាពរបស់អ្នក បន្ទាប់ពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៣ ។ បញ្ជីនេះនឹងប្រាប់អ្នកដែលយើងបានប្រាប់ពីព័ត៌មាន នៅពេលណា មូលហេតុអ្វីខ្លះ និងព័ត៌មានអ្វីខ្លះ ត្រូវបានប្រាប់ហើយ ។ បញ្ជីនេះនឹងមិននិយាយថា តើយើងបានផ្តល់ព័ត៌មានដល់អ្នកនៅពេលណា ឬថាតើយើងបានផ្តល់ព័ត៌មានដោយមានការអនុញ្ញាតរបស់អ្នកនៅពេលណា ឬថាតើយើងបានប្រាប់ព័ត៌មានពីការព្យាបាល ការបង់ថ្លៃ ឬដំណើរការថែទាំសុខភាពនៅពេលណានោះទេ ។
- អ្នកមានសិទ្ធិទទួលឯកសារ ស្តីពីសេចក្តីជូនដំណឹងនៃការសម្ងាត់នេះ នៅពេលដែលអ្នកស្នើសុំវា ។ អ្នកក៏អាចរកបាននូវសេចក្តីជូនដំណឹងនេះ តាមរយៈគេហទំព័ររបស់ BCCTP: http://dhcs.ca.gov/BCCTP. ។

**តើអ្នកទាក់ទងពួកយើងដើម្បីប្រើសិទ្ធិរបស់អ្នកយ៉ាងដូចម្តេច?**

ប្រសិនបើអ្នកចង់ប្រើប្រាស់សិទ្ធិសម្ងាត់ណាមួយ ដែលបានពន្យល់នៅក្នុងសេចក្តីជូនដំណឹងនេះ សូមមេត្តាទូរស័ព្ទ សរសេរ ឬអ៊ីមែលមកយើងខ្ញុំតាមអាស័យដ្ឋាន ឬលេខទូរស័ព្ទនៅក្នុងប្រអប់ខាងក្រោម ។ យើងខ្ញុំនឹងផ្ញើឱ្យអ្នកនូវសំណុំបែបបទដែលអ្នកត្រូវការ ។

**Privacy Officer**
Department of Health Care Services
MS 0100
PO Box 997413
Sacramento, CA 95899-7413
(916) 445-4646 or (877) 735-2929 TTY/TDD
http://dhcs.ca.gov/privacyoffice

**បណ្តឹង**

ប្រសិនបើអ្នកជឿថា យើងមិនបានការពារការសម្ងាត់របស់អ្នកទេ អ្នកអាចប្តឹងដោយទាក់ទងមន្ត្រីរក្សាការសម្ងាត់នៅក្រសួងសេវាសុខភាពការលីហ្វញ៉ា តាមអាស័យដ្ឋានខាងលើ ឬតាមគេហទំព័ររបស់យើង : http://dhcs.ca.gov/privacyoffice.

អ្នកក៏អាចទូរស័ព្ទ ឬសរសេរសំបុត្រទៅកាន់ Secretary of the Department of Health and Human Services, U.S. Office for Civil Rights, 90 7th Street, Suite 4-100, San Francisco, CA 94103. ។

ឬអ្នកអាចទូរស័ព្ទទៅការិយាល័យសិទ្ធិពលរដ្ឋរបស់សហរដ្ឋអាមេរិកតាមលេខទូរស័ព្ទ : 866-OCR-PRIV (866-627-7748) or 866-788-4989 TTY/TDD.

**ផលប្រយោជន៍របស់អ្នកមានសុវត្ថិភាព**

កម្មវិធី BCCTP មិនអាចធ្វើឱ្យបាត់ប្រយោជន៍ថែទាំសុខភាពរបស់អ្នកទេ ឬមិនអាចធ្វើអ្វីមួយ ឱ្យអ្នកឈឺចាប់ទេ ប្រសិនបើអ្នកសម្រេចចិត្តប្តឹង ឬប្រើប្រាស់សិទ្ធិសម្ងាត់ណាមួយនៅក្នុងសេចក្តីជូនដំណឹងនេះ ។

**តើអ្នកមានសំណួរទេ ?**

ប្រសិនបើអ្នកមានសំណួរអំពីសេចក្តីជូនដំណឹងនេះ ហើយត្រូវការព័ត៌មានបន្ថែម សូមមេត្តាទាក់ទងមន្ត្រីរក្សាការសម្ងាត់នៅក្រសួងសេវាថែទាំសុខភាព កាលីហ្វញ៉ា ដែលបានចុះក្នុងសេចក្តីជូនដំណឹងនេះ ឬតាមគេហទំព័ររបស់យើង : http://dhcs.ca.gov/privacyoffice.

**ការកែប្រែចំពោះសេចក្តីជូនដំណឹងស្តីអំពីការសម្ងាត់**

កម្មវិធី BCCTP ត្រូវតែគោរពសេចក្តីជូនដំណឹងនេះ ដែលចូលជាធរមាននៅថ្ងៃទី១៤ ខែ មេសា ឆ្នាំ២០០៣។ យើងមានសិទ្ធិកែប្រែការសម្ងាត់របស់យើង ។ ប្រសិនបើយើងធ្វើការកែប្រែ យើងនឹងកែប្រែសេចក្តីជូនដំណឹងនេះ ហើយប្រគល់ជូនសេចក្តីជូនដំណឹងនេះទៅឱ្យអ្នកភ្លាម ។

ដើម្បីទទួលសេចក្តីជូនដំណឹងនេះមួយច្បាប់ ជាភាសាផ្សេងៗទៀត អក្សរសម្រាប់មនុស្សខ្វាក់បោះពុម្ពធំ កាសែតស្តាប់ ឬឌីសកុំព្យូទ័រ សូមមេត្តាទាក់ទងមន្ត្រីរក្សាការសម្ងាត់នៅក្រសួងសេវាសុខភាព កាលីហ្វញ៉ា ដែលបានចុះក្នុងសេចក្តីជូនដំណឹងនេះ ឬតាមគេហទំព័រ http://dhcs.ca.gov/privacyoffice.

**រដ្ឋកាលីហ្វញ៉ា**
**ទីភ្នាក់ងារផ្តល់សេវាសុខភាព និងមនុស្ស**

**Arnold schwarzenegger**
**អភិបាលរដ្ឋ**

## ក្រសួងសេវាថែទាំសុខភាព
## កាលីហ្វញ៉ា

## សារមកពីកម្មវិធីព្យាបាល
## ជម្ងឺមហារីកសុដន់ និងដោះ
## (BCCTP)

សេចក្តីជូនដំណឹងស្តីពី
ការសម្ងាត់

ចូលជាធរមាននៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៣

**សេចក្តីជូនដំណឹងនេះ ពិពណ៌នាពីថាតើពត៌មានវេជ្ជសាស្ត្រស្តីអំពីអ្នក អាចត្រូវបានគេប្រើ និងលាតត្រដាងយ៉ាងដូចម្តេច និងថាតើអ្នកអាចមានឱកាសទទួលព័ត៌មាន នេះយ៉ាងដូចម្តេច ។ សូមពិនិត្យពត៌មាននេះឡើងវិញដោយប្រុងប្រយ័ត្ន**

អ្នកនឹងទទួលសេចក្តីជូនដំណឹងនេះ ពីព្រោះអ្នកបានចុះឈ្មោះក្នុងកម្មវិធីព្យាបាល ជម្ងឺមហារីកសុដន់ និងដោះ ដែលផ្តល់មូលនិធិដោយរដ្ឋ

BCCTP Notice of Privacy Practices (Khmer)

**កម្មវិធីព្យាបាលជម្ងឺមហាស្បូន និងដោះ (BCCTP)** ត្រូវតែរក្សាព័ត៌មានសុខភាពរបស់អ្នកជាសម្ងាត់ ។ យើងទទួលព័ត៌មានអំពីអ្នក នៅពេលដែល អ្នកដាក់ពាក្យសុំសេវាកម្ម និងនៅពេលដែលគេធ្វើការទំនាក់ទំនងជាមួយកម្មវិធី BCCTP វេជ្ជបណ្ឌិត គ្លីនិក និងអ្នកផ្សេងៗទៀត ស្តីអំពីលក្ខខណ្ឌគ្រប់គ្រាន់ BCCTP របស់អ្នក។ យើងអាចទទួលព័ត៌មាន វេជ្ជសាស្ត្រស្តីអំពីការព្យាបាលជម្ងឺមហារីក របស់អ្នក មុន ឬបន្ទាប់ពីការដាក់ពាក្យសុំ BCCTP របស់អ្នក ត្រូវបានអនុម័ត ។ យើងត្រូវតែផ្តល់ឱ្យអ្នក នូវសេចក្តីជូន ដំណឹងនេះ ស្តីពីថាតើច្បាប់អនុញ្ញាតឱ្យ យើងប្រើ ប្រាស់ និងប្រាប់ព័ត៌មានសុខភាពរបស់អ្នក និងថាតើសិទ្ធិរបស់អ្នកគឺជាអ្វី ។

## ថាតើយើងអាចប្រើប្រាស់ និងប្រាប់ព័ត៌មាន ស្តីពីអ្នកយ៉ាងដូចម្តេច

កម្មវិធីព្យាបាលជម្ងឺមហារីក និងដោះ (BCCTP) ប្រើប្រាស់ និងប្រាប់ព័ត៌មានស្តីពីអ្នក ក្នុងការចាត់ចែង កម្មវិធី BCCTP ។ ព័ត៌មាននេះរួមមាន ឈ្មោះរបស់ អ្នក អាស័យដ្ឋាន ព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានវេជ្ជសាស្ត្រ ព័ត៌មានធានាសុខភាពផ្សេងៗទៀត និងការថែទាំសុខភាពដែលអ្នកបានទទួល ។ យើងប្រើព័ត៌មាននេះ ហើយប្រាប់អ្នកដទៃដោយហេតុផលដូចខាងក្រោម :

•**សម្រាប់ការព្យាបាលៈ** យើងអាចទទួលព័ត៌មានពី វេជ្ជបណ្ឌិត មន្ទីរពេទ្យ គម្រោងធានាសុខភាពនានា និងអ្វីផ្សេងៗទៀត នៅពេលធ្វើការប្តេជ្ញាចិត្ត ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ដែលធ្វើឱ្យអ្នកអាច ទទួលការព្យាបាលជម្ងឺមហារីក និងសេវាកម្ម ដែលពាក់ព័ន្ធក្រោមកម្មវិធី BCCTP ។ វេជ្ជបណ្ឌិតរបស់អ្នក និងបុគ្គលិកថែទាំសុខភាព ផ្សេងៗទៀត អាចផ្តល់ព័ត៌មានពីការថែទាំសុខ ភាព ដែលអ្នកបានទទួល និងព័ត៌មានស្តីពីលទ្ធផល នៃការថែទាំសុខភាពនោះ និងព័ត៌មានស្តីពី ការ ថែទាំសុខភាពផ្សេងៗទៀត ដែលអ្នកអាចត្រូវការ ទាក់ទងនឹងការពិនិត្យ និងការវិភាគរោគជម្ងឺ មហារីក និងប្រសិនបើអ្នកត្រូវការ ការព្យា បាលជម្ងឺ ។

•**សម្រាប់ការបង់ថ្លៃ :** កម្មវិធី BCCTP និងអ្នក ដទៃទៀតសហការជាមួយយើងពិនិត្យឡើងវិញ អនុម័ត និងបង់ថ្លៃការថែទាំសុខភាព ដែលចាត់ ចែងដោយវេជ្ជជំនួសអ្នក ។ នៅពេលដែលយើងធ្វើ បែបនេះ គ្លីនិក និងអ្នកដទៃទៀត ដែលបង់ថ្លៃការ ថែទាំសុខភាពរបស់អ្នក ។

•**សម្រាប់ប្រតិបត្តិការថែទាំសុខភាព :** កម្មវិធី BCCTP អាចប្រើប្រាស់របាយការណ៍វេជ្ជសាស្ត្រ របស់អ្នក ដើម្បីពិនិត្យឡើងវិញពីគុណភាពនៃការ ការក្លែងបន្លំ និងចាត់ចែង កម្មវិធី BCCTP ។

## អាចប្រាប់ពីព័ត៌មានរបស់អ្នក

ច្បាប់ក៏អនុញ្ញាតឱ្យ BCCTP ប្រើប្រាស់ ឬជូនព័ត៌មានដែលយើងមានស្តីអំពីអ្នកតាមគោលបំណងដូចខាងក្រោម :

- ដើម្បីទូរស័ព្ទ ឬសរសេរសំបុត្រជូនអ្នក ស្តីអំពីផលប្រយោជន៍របស់អ្នក ក្រោមកម្មវិធីព្យាបាលជម្ងឺមហារីកស្បូន និងដោះ (BCCTP) ។
- សម្រាប់សកម្មភាពសុខភាពសាធារណៈនានា ដូចជាការរាយការណ៍នៅពេលដែលជម្ងឺកើតឡើង ។
- សម្រាប់ករណីបណ្តឹងផ្លូវច្បាប់ និងរដ្ឋបាល ដូចជា ឆ្លើយតបទៅនឹងដីកាតុលាការណាមួយ ។
- សម្រាប់ការសិក្សាស្រាវជ្រាវដែលបំពេញតាមតម្រូវការច្បាប់ឯកជនទាំងអស់ដូចជា ការស្រាវជ្រាវដែលទាក់ទងនឹងការបង្ការ និងព្យាបាលជម្ងឺ ។
- សម្រាប់គោលបំណងនានាដែលតម្រូវដោយច្បាប់ ដូចជាការរាយការណ៍ពីការរំលោភ ឬការប្រមាថ ឬសំណងរបស់បុគ្គលិក ។
- ចំពោះទីភ្នាក់ងារនានាដែលមើលខុសត្រូវប្រព័ន្ធថែទាំសុខភាពសម្រាប់សវនកម្ម ឬការស៊ើបអង្កេត ។
- ក្នុងការស្នើសុំការសម្រេចចិត្តអំពីការទាមទារការថែទាំសុខភាព ដែលបានធ្វើឡើង ឬបដិសេធដោយ BCCTP ។
- ចំពោះរដ្ឋាភិបាលសហព័ន្ធ នៅពេលខ្លួនកំពុងពិនិត្យថាតើយើងបំពេញតាមច្បាប់ឯកជនយ៉ាងដូចម្តេច ។
- ចំពោះទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត ដែលផ្តល់ផលប្រយោជន៍សាធារណៈ
- ដើម្បីបង្កើតឱ្យមានព័ត៌មានជាច្រើន ដែលគេមិនអាចតាមដានអ្នកទៀតឡើយ ។

យើងអាចផ្តល់ព័ត៌មានផ្នែកសុខភាពអំពីអ្នកឱ្យទៅអង្គការនានា ដែលជួយយើងនៅក្នុងប្រតិបត្តិការនានារបស់យើង ដូចជា តាមរយៈការស្នើសុំឱ្យមានសេវាកម្មដែលអ្នកទទួលក្រោមកម្មវិធី BCCTP ។ ប្រសិនបើយើងធ្វើ យើងនឹងធានាឱ្យប្រាកដថា ពួកគេការពារការសម្ងាត់របស់ព័ត៌មាន ដែលយើងចែករំលែកជាមួយពួកគេ ។

ច្បាប់រដ្ឋមួយចំនួន កម្រិតការចែករំលែកព័ត៌មានដែលបានពិពណ៌នាខាងលើ ។ ឧទាហរណ៍ មានច្បាប់ពិសេសជាច្រើនដែលការពារព័ត៌មានពីស្ថានភាព HIV/AIDS ការព្យាបាលសុខភាពផ្លូវចិត្ត ពិការភាព និងការព្យាបាលជម្ងឺញៀនថ្នាំ និងស្រា ។ យើងនឹងគោរពច្បាប់ទាំងអស់នេះ ។

## នៅពេលគេត្រូវការការអនុញ្ញាតជាលាយលក្ខណ៍អក្សរ

មុនកម្មវិធី BCCTP ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដោយហេតុផលណាមួយដែលមិនបានចុះខាងលើ យើងនឹងទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នក។ ប្រសិនបើអ្នកពិតជាផ្តល់ឱ្យយើងនូវការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ហេតុផលផ្សេងៗទៀត អ្នកអាចដកយកវិញនូវការអនុញ្ញាតជាលាយលក្ខណ៍អក្សរនៅពេលណាក៏បាន ។

## ក្រោមច្បាប់ តើអ្វីទៅជាសិទ្ធិឯកជនរបស់អ្នក ?

អ្នកមានសិទ្ធិ :

- ឱ្យយើងទាក់ទងអ្នក តាមរយៈការសរសេរ ឬតាមអាស័យដ្ឋាន ប្រអប់ប៉ុស្តិ៍ប្រៃសណីយ៍ ឬលេខទូរស័ព្ទដោយឡែកមួយ ។ យើងនឹងទទួលការស្នើសុំដែលសមហេតុផល នៅពេលណាចាំបាច់ក្នុងការការពារការសម្ងាត់ និងសុវត្ថិភាពរបស់អ្នក ។
- មើល និងទទួលព័ត៌មានមួយច្បាប់ ដែលកម្មវិធី BCCTP មាន ស្តីអំពីអ្នក ។ កម្មវិធី BCCTP មានព័ត៌មានពីលក្ខខណ្ឌគ្រប់គ្រាន់ និងព័ត៌មានវេជ្ជសាស្ត្រមួយចំនួនដែលយើងប្រើ ដើម្បីអនុម័តលក្ខខណ្ឌគ្រប់គ្រាន់របស់អ្នក ដើម្បីទទួលសេវាក្រោមកម្មវិធី BCCTP ។ គេអាចគិតថ្លៃដល់អ្នកសម្រាប់តម្លៃថតចម្លង និងផ្ញើរបាយការណ៍ទាំងអស់ ឬដោយផ្នែកនៃរបាយការណ៍របស់អ្នក ដោយហេតុផលដែលអនុញ្ញាតដោយច្បាប់ ។ ប្រសិនបើយើងធ្វើ យើងនឹងជូនដំណឹងដល់អ្នកស្តីអំពីថា តើត្រូវសុំការសម្រេចចិត្តយ៉ាង ដូចម្តេច ។
- កែប្រែរបាយការណ៍ ប្រសិនបើអ្នកជឿថា ព័ត៌មានមួយចំនួនដែលយើងមាននៅក្នុងរបាយការណ៍របស់យើងស្តីអំពីអ្នក មិនត្រឹមត្រូវ ។ យើងអាចបដិសេធការស្នើសុំរបស់អ្នក ប្រសិនបើព័ត៌មានមិនត្រូវបាន ធ្វើឡើង ឬរក្សាដោយកម្មវិធី BCCTP ឬប្រសិនបើព័ត៌មាននោះមានលក្ខណៈត្រឹមត្រូវ ហើយពេញលេញរួចជាស្រេចហើយនោះ ។ ប្រសិនបើការស្នើសុំរបស់អ្នកត្រូវគេបដិសេធ អ្នកអាចសរសេរសំបុត្រមួយ ច្បាប់ដោយមិនយល់ស្របជាមួយការសម្រេចចិត្ត របស់យើង ហើយសំបុត្ររបស់អ្នកនឹងត្រូវរក្សាជាមួយនឹងរបាយការណ៍របស់យើង ។

ຖ້າທ່ານຕ້ອງການສຳເນົາໃບແຈ້ງການກ່ຽວກັບການ ປະຕິບັດຕໍ່ສິດທິຄວາມເປັນສ່ວນຕົວ ບຸກຄົນ ທີ່ກ່ຽວຂ້ອງກັບສິດທິຄວາມເປັນສ່ວນ ຕົວບຸກຄົນຂອງທ່ານ, ໂທເບີ (916) 445-4546 (Laotian)

「隱私權管理方法通知」闡述了您的隱私權，如果您想要索取一份，請致電 (916) 445-4546 (Mandarin)

ਜੇ ਤੁਸੀਂ ਜਾਣਕਾਰੀ ਨੂੰ ਗੁਪਤ ਰੱਖਣ ਦੇ ਵਿਹਾਰ ਦੀ ਕਾਪੀ ਲੈਣੀ ਚਾਹੁੰਦੇ ਹੋ, ਜੋ ਕਿ ਜਾਣਕਾਰੀ ਨੂੰ ਗੁਪਤ ਰੱਖਣ ਦੇ ਤੁਹਾਡੇ ਅਧਿਕਾਰ ਬਾਰੇ ਹੈ, ਤਾਂ ਇਸ ਨੰਬਰ 'ਤੇ ਫ਼ੋਨ ਕਰੋ: (916) 445-4546 (Punjabi)

Если вы хотите получить экземпляр “Уведомления о практике сохранения конфиденциальности информации”, содержащего информацию о ваших правах на сохранение конфиденциальности, позвоните по телефону (916) 445-4546 (Russian)

Si desea una copia del Aviso sobre Prácticas de Privacidad que explica sus derechos a la privacidad, llame al: (916) 445-4546 (Spanish)

Kung gusto ninyo ng kopya ng Paunawa Tungkol sa Hindi Pagsisiwalat ng Impormasyon, na nauukol sa inyong mga karapatan sa privacy, tawagan ang (916) 445-4546 (Tagalog)

Nếu quý vị muốn nhận được một bản Thông Tri Thực Hành Bảo Mật, nói về quyền riêng tư của quý vị, xin vui lòng gọi (916) 445-4546 (Vietnamese)